ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ សរ.ណណ

# សារាចរណែនាំ

## ស្ដីពី

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤

### I. សេចក្ដីផ្ដើម

១- មាត្រា ៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ដំណាក់កាលគឺ (១)ដំណាក់កាលទី១: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២)ដំណាក់កាលទី២: ការរៀបចំកញ្ចប់ថវិកាពីខែមិថុនា ដល់ខែកញ្ញា និង(៣)ដំណាក់កាលទី៣: ការអនុម័តថវិកាពីខែតុលា ដល់ខែធ្នូ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ នៃការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ សារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា នៅដើមខែមេសា សម្រាប់ដំណាក់កាលទី១ និងសារាចរណែនាំស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី២។ ដូច្នេះ សារាចរនេះគឺជាមគ្គុទ្ទេសក៍សម្រាប់ណែនាំ និងជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤-២០១៦ ដល់គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់សម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ដោយឡែក សារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

២- ផែនការយុទ្ធសាស្ត្រថវិកាគឺជាឧបករណ៍ និងជាយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ថវិកាតាមរយៈការជួយតម្រង់ និងជំរុញឲ្យការវិភាជថវិកាចំទិសដៅ ការវិភាជថវិកាបម្រើឲ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្ដែង ដើម្បីសម្រួចរាល់ចំណាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត បម្រើទាំងស្រុង និងសម្រេចឲ្យបាននូវគោលនយោបាយជាយុទ្ធសាស្ត្រនិងអាទិភាពរបស់ក្រសួង ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់វិស័យនីមួយៗ សម្រាប់រួមចំណែកសម្រេចឲ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រថវិកានេះគឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ជានា

និរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព និង(៥) ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និងការវិភាជថវិកា។ ដូច្នេះ គឺជាតម្រូវការចាំបាច់ដែលគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាជារៀងរាល់ឆ្នាំ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ មិនត្រឹមតែបាននិងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការវិភាជ ការប្រើប្រាស់ និងការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មថវិកាចរន្ត និង ថវិកាបុលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូរអភិវឌ្ឍន៍ឲ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ។ ដើម្បីឲ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះអាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេសដោយផែនការយុទ្ធសាស្ត្រថវិកានេះ តម្រូវឲ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល និងបញ្ចូលទាំងថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួងស្ថាប័ននីមួយៗ ត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគម្រោង។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យសម្រេច និងចុះហត្ថលេខា។ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៤-២០១៦ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា) ឲ្យបានត្រឹមថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអាចអញ្ជើញតំណាង ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិវិភាជកញ្ចប់ថវិកា ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤- តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១២អាចសម្រេចបាន៧,៣% ក្នុងនោះ វិស័យកសិកម្មអាចសម្រេចបានកំណើន៤,៣% វិស័យឧស្សាហកម្មអាចសម្រេចបានកំណើន៩,២% និងវិស័យសេវាកម្មអាចសម្រេចបានកំណើន៨,១%។

៥- តាមការព្យាករដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៣នេះ អាចនឹងបន្តសម្រេចបាន៧% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៤% ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ ដំឡូងមី កៅស៊ូ និងអំពៅ។ វិស័យឧស្សាហកម្មនឹងមានកំណើន១០% ដោយសារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការរីកចម្រើនវិស័យឧស្សាហកម្មធុនស្រាល និងផលិតផលនៃច្រវាក់ផ្គត់ផ្គង់សាកល។ វិស័យសេវាកម្មនឹងមានកំណើន៦,៥% ដែលកំណើននេះបានមកពីកំណើនវិស័យដឹកជញ្ជូននិងទូរគមនាគមន៍ វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។

៦- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ តាមការព្យាករអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៣,៨% ដោយសារការកើនឡើងនៃកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងតម្រូវការទីផ្សារអន្តរជាតិ មានដូចជា ស្រូវ ពោត ដំឡូងមី កៅស៊ូ និងអំពៅ ជាដើម។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ១០% ដោយរំពឹងថាវិស័យវាយនភណ្ឌនឹងអាចកើនឡើងប្រមាណ៩,៩% ដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តមិនយកពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខ លើកលែងតែសព្វាវុធ" និងសក្តានុពលដែលអាចពង្រីកផលិតកម្មនិងទីផ្សារនៃវិស័យនេះ។ ម្យ៉ាងទៀត គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករក៏បានជំរុញឲ្យមានការកើនឡើងខ្ពស់ខាងវិស័យកែច្នៃម្ហូបអាហារ និងវិស័យដែលទាក់ទងមួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងអគ្គិសនីប្រើប្រាស់ធ្យូងថ្មនឹងត្រូវបានដាក់ឲ្យដំណើរការជាបន្តបន្ទាប់ និងឧស្សាហកម្មធុនស្រាលដទៃទៀតក៏បង្កើនសកម្មភាពកាន់តែខ្លាំងក្លាដែរ។ វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ ៦,៨% ដោយសារការកើនឡើងវិស័យទេសចរណ៍ វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។ វិស័យហិរញ្ញវត្ថុដែលជាស្នូលទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចទូទៅនឹងបន្តកើនឡើងក្នុងល្បឿនលឿននិងស្ថិរភាពគោលនយោបាយរូបិយវត្ថុក្នុងនោះមានការជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងគោលនយោបាយសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យឧស្សាហកម្ម។ វិស័យអចលនទ្រព្យនិងសំណង់នឹងបន្តកើនឡើងដោយសារតម្រូវការមានការកើនឡើងតាមរយៈលំហូរទុនចូលពីវិនិយោគបរទេស និងកំណើនសេដ្ឋកិច្ចខ្ពស់។

៧- អតិផរណានៅឆ្នាំ២០១២ មានចំនួន២,៩% ការសម្រេចបានអតិផរណាកម្រិតទាបនេះដោយសារមានការគ្រប់គ្រងប្រុងប្រយ័ត្នបំផុតទៅលើគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈក្នុងការបង្កើនសកម្មភាពសេដ្ឋកិច្ច-សង្គមកិច្ច ទោះបីជាអតិផរណានៅក្នុងតំបន់ និងពិភពលោកមានកម្រិតខ្ពស់ ហើយប្រាក់ដុល្លារគ្មានស្ថិរភាពក៏ដោយ។ តាមការប៉ាន់ស្មាន អតិផរណានៅឆ្នាំ២០១៣ នឹងមានកម្រិត៤% គឺដូចទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយសារតម្រូវការចំណាយនៅក្នុងឆ្នាំ២០១៣ នឹងមានកំណើនខ្ពស់ ទាំងផ្នែកសាធារណៈទាំងផ្នែកឯកជន រួមទាំងការចំណាយសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភានីតិកាលទី៥ ជាដើម។ តាមការព្យាករ អតិផរណាប្រចាំឆ្នាំ២០១៤ នឹងមានកម្រិត៣,៥% ដោយសារមានស្ថិរភាពថ្លៃម្ហូបអាហារ និងស្ថិរភាពហិរញ្ញវត្ថុ។

៨- អត្រាប្តូរប្រាក់នៅឆ្នាំ២០១២ មានតម្លៃជាមធ្យម ៤ ០៣៤រៀលក្នុង១ដុល្លារអាមេរិក។ តាមការប៉ាន់ស្មាន អត្រាប្តូរប្រាក់នៅឆ្នាំ២០១៣ នឹងមានតម្លៃជាមធ្យម ៤ ០០០រៀលក្នុង១ដុល្លារអាមេរិក គឺដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ប៉ុន្តែខ្ពស់ជាងធៀបនឹងការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលមានតម្លៃ ៤ ០៥០រៀលក្នុង១ដុល្លារអាមេរិក។ ការឡើងថ្លៃប្រាក់រៀលគឺដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន និងជាពិសេសគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្រប។ តាមការព្យាករ នៅឆ្នាំ២០១៤ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ ៤ ០០០រៀលក្នុង១ដុល្លារ

អាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាគុណភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

៩-ឱនភាពគណនីចរន្តបានកើនឡើងវិញគឺពី-៣,៧៨%នៃផសសនៅឆ្នាំ២០១១ មក -៦,៦៣%នៃផសសនៅឆ្នាំ២០១២ ដោយសារការកើនឡើងការនាំចូលវត្ថុធាតុដើម និងឧបករណ៍បរិក្ខាផលិតកម្មនៃវិនិយោគផ្ទាល់ពីបរទេស។ តាមការព្យាករ ឱនភាពគណនីចរន្តនឹងធ្លាក់ចុះបន្តិចមកវិញនៅត្រឹម-៦,៤២%នៃផសសនៅឆ្នាំ២០១៣ និង-៦,៣៥%នៃផសសនៅឆ្នាំ២០១៤។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាបានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលរេ និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឲ្យការនាំចូលជាបណ្តើរៗ។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១២ មានចំនួន ៣ ២៦៥លានដុល្លារអាមេរិក ឬប្រមាណ៤,៩ខែនៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ អាចកើនឡើងលើសពី ៤ពាន់លានដុល្លារអាមេរិក ដែលអាចធានាបានប្រមាណជាង ៤,៥ខែនៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។

១០-ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ការបង្កើនការងារធ្វើ និងចីរភាពបំណុល។ ដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ពោលគឺបន្តខិតខំដើម្បី (១)សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៧% (២)រក្សាអត្រាអតិផរណាឲ្យស្ថិតនៅក្រោម ៥% (៣)កំណត់បំណុលបរទេសឲ្យមានកម្រិតប្រហាក់ប្រហែលនឹងលំហូរនៃហិរញ្ញប្បទាននិងការវិនិយោគផ្ទាល់ពីបរទេស និង(៤)រក្សាទុនបម្រុងអន្តរជាតិឲ្យស្មើនឹងការនាំចូលចំនួនបីខែ។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើនផសសពិតឲ្យសម្រេចបានក្នុងរង្វង់៧% នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ និងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឲ្យស្ថិតក្នុងរង្វង់៤% ក្នុងឆ្នាំ២០១៣ និង៣,៥% ក្នុងឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានារក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលឲ្យស្ថិតនៅក្នុងរង្វង់ ៤ ០០០រៀលក្នុង១ដុល្លារអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបិយកម្មសេដ្ឋកិច្ចនៅចំពោះមុខ និងរយៈពេលវែងតាមរយៈការលើកកម្ពស់គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ លើសពីនេះ សម្រាប់រយៈពេលមធ្យមខាងមុខ(២០១៤-២០១៦) រាជរដ្ឋាភិបាលមានគោលដៅរក្សាកំណើនប្រចាំឆ្នាំឲ្យបានក្នុងរង្វង់៧% អត្រាអតិផរណាក្នុងរង្វង់៤% និងអត្រាប្តូរប្រាក់រៀលក្នុងរង្វង់៤ ០០០រៀលក្នុង១ដុល្លារអាមេរិក។

## **ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

១១- គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៤-២០១៦មានគោលដៅសំខាន់ៗដូចតទៅ ៖

- ធានាបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល*ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន* ដោយធានាបានទាំងស្រុងនូវការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលផ្តល់អាទិភាពទៅលើ៖

- បន្តលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។
- បន្តបង្កើនការលើកស្ទួយវិស័យកសិកម្មតាមរយៈការលើកកម្ពស់ផលិតភាពនិងពិពិធកាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។
- បន្តបង្កើនការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមរយៈការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍវិស័យថាមពលនិងបណ្តាញអគ្គិសនី និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។
- បន្តអភិវឌ្ឍផ្នែកឯកជននិងការងារតាមរយៈការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិត ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។
- បន្តកសាងសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយយេនឌ័រ និងការអនុវត្តគោលនយោបាយប្រជាជន។

- ធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព។
- ធានាបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៤-២០១៦។
- ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។
- ធានាបន្តអនុវត្តគោលនយោយបាយចាស់សកម្មភាពថ្មីនៃវិស័យដីធ្លី ពិសេសការវាស់វែងនិងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋនិងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញរង្គរ។
- ធានាបង្កើនចំណាយវិនិយោគក្នុងស្រុកដោយខិតខំសន្សំពីអតិរេកថវិកាចរន្ត ដើម្បីកាត់បន្ថយជាបណ្តើរៗនូវចំណាយវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេស ក្នុងគោលដៅរក្សាឱនភាពថវិកាសរុបឲ្យស្ថិតនៅក្រោម-៥%នៃផសស។
- ធានាបន្តការពារឲ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុកមង្គលជូនប្រជាពលរដ្ឋ។
- ពង្រឹង និងបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ដែលបានប្រើប្រាស់ក្នុងអំឡុងពេលមានវិបត្តិកន្លងមក។
- ធានាផ្តល់ការឆ្លើយតបដោយទាន់ពេលវេលា និងដោយប្រសិទ្ធភាពចំពោះវិបត្តិ និងឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដូចជាគ្រោះធម្មជាតិជាដើម។

១២- ដើម្បីសម្រេចបានតាមគោលដៅខាងលើ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៤-២០១៦ មានគោលដៅបង្កើនការប្រមូលចំណូលឲ្យមានកំណើនប្រមាណ០,៥%នៃផសស ក្នុងមួយឆ្នាំ ហើយពង្រឹងវិន័យ និងបង្កើនគុណភាពចំណាយដោយបន្តរឹតត្បិតចំណាយចរន្តតាមរយៈការធ្វើវិចារណកម្ម និងការធ្វើអាទិភាវូបនីយកម្មចំណាយជាមួយនឹងការបង្កើនចំណាយវិនិយោគ ក្នុងគោលដៅរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងរង្វង់៣%នៃផសស និងឱនភាពថវិកាសរុបឲ្យស្ថិតក្រោម៥%នៃផសសក្នុងមួយឆ្នាំ។ ដើម្បីសម្រេចគោលដៅនេះ ថវិកាឆ្នាំ២០១៣ និងឆ្នាំ២០១៤ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណូលសរុបនៅឆ្នាំ២០១៣ ត្រូវសម្រេចឲ្យបាន១៤,៧%នៃផសស ក្នុងនោះចំណូលចរន្តត្រូវសម្រេចឲ្យបាន១៤,៥៦%នៃផសស និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន ០,១៣%នៃផសស។ ចំណូលចរន្តដែលត្រូវសម្រេចឲ្យបាន១៤,៥៦%នៃផសស គឺ ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៥២%នៃផសស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៥៦%នៃផសស ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣៦%នៃផសស និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៣%នៃផសស។ ចំណូលសរុបសម្រាប់ឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣%នៃផសស ក្នុងនោះចំណូលចរន្តត្រូវសម្រេចឲ្យបាន១៥,០៦%នៃផសស និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន០,១៧%នៃផសស។ ចំណូលចរន្តដែលត្រូវសម្រេចឲ្យបាន១៥,០៦%នៃផសស គឺចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវសម្រេចឲ្យបាន៦,៧០%នៃផសស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៩០%នៃផសស ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣១%នៃផសស និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៤%នៃផសស។
- ចំណាយសរុបត្រូវរក្សាឲ្យនៅត្រឹម២០,០៩%នៃផសស នៅឆ្នាំ២០១៣ ដោយចំណាយចរន្តត្រូវរក្សាឲ្យបានត្រឹម១២,០៧%នៃផសស និងចំណាយមូលធនត្រឹម៨,០២%នៃផសស។ ចំណាយសរុបសម្រាប់ឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣%នៃផសស ដោយចំណាយចរន្តនឹងកម្រិតត្រឹម១២,០៦%នៃផសស ដោយក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្ស ដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណានិងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថិរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ ចំណាយមូលធននឹងរក្សាត្រឹម ៨,០៧%នៃផសស។

១៣- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ ថវិកាឆ្នាំ២០១៤ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម៖

ផ្នែកចំណូល

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឲ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការធ្វើអធិការកិច្ចនិងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។
- ពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ពិសេសការបង់ពន្ធ និងការបង់ចំណែកនៃប្រាក់ចំណេញជូនរដ្ឋ។
- បន្តស្រាវជ្រាវ និងកំណត់ឲ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលពន្ធ និងមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារប៉េះប៉ះគាមគ្រប់មុខសញ្ញាទាំងអស់។ ចំពោះបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ ចំណូលពីការជួលរោងចក្រ សហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត និងចំណូលពីឯកជនភាវូបនីយកម្មនិងការលក់ទ្រព្យសម្បត្តិរដ្ឋ។
- បន្តពង្រឹង និងជំរុញឲ្យបានជោគជ័យនូវវិធានការកែទម្រង់ការគ្រប់គ្រងកម្រៃសេវារដ្ឋបាលរបស់រដ្ឋដែលទើបនឹងត្រូវបានដាក់ចេញក្នុងពេលថ្មីៗកន្លងមក។
- រៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។
- អនុវត្តផែនការសកម្មភាព និងអាទិភាពដែលបានរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ ដូចជាពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពីការរៀបចំសេចក្តីព្រាងប្រកាសស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ សេចក្តីព្រាងប្រកាសស្តីពីវិធានការនិងនីតិវិធីបណ្តឹងតវ៉ា រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងនិងប្រមូលបំណុលពន្ធ សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌របស់មន្ត្រីពន្ធដារ សេចក្តីព្រាងអនុក្រឹត្យស្តីពីវិសោធនកម្មអត្រាអាករពិសេសលើផលិតផលថ្នាំជក់ និងបារី ព្រមទាំងរៀបចំផែនការសកម្មភាព និងអាទិភាពក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត។
- ជំរុញឲ្យមានការស្រាវជ្រាវប្រភពចំណូលថ្មី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនចំណូលបង់ចូលថវិការដ្ឋ។ សម្រាប់ថ្នាក់ក្រោមជាតិ ជំរុញការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងសវនកម្មលើការប្រមូលចំណូលគ្រប់ប្រភេទ រួមទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។

ផ្នែកចំណាយ

- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាពសង្គម កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ព្រមទាំងការពង្រីកការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន មន្ទីរពេទ្យ ។ល។

- បន្តលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងការចាត់ចែងចំណាយចាប់តាំងពីដំណាក់កាលនៃការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងសវនកម្មលើលទ្ធផលនៃការអនុវត្តថវិកា។
- រៀបចំ និងអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំងពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។
- បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងបន្តពង្រឹងការរៀបចំថវិកាឲ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការបន្តពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូលនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឲ្យបានច្បាស់លាស់និងសុក្រឹត ការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី និងការធ្វើសមាហរណកម្មថវិកា។
- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹងនិងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស ឆមាសនិងឆ្នាំ និងការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាននៅក្នុងជំហានទី១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់និងចាំបាច់សម្រាប់អនុវត្តកម្មវិធីជំហានទី២ គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ និងបណ្តាជំហានបន្តបន្ទាប់ទៀត។
- បន្តរៀបចំនិងត្រៀមដាក់ឲ្យអនុវត្តប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុឲ្យកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅ ជាពិសេសចាប់ផ្តើមកំណត់ និងដាក់ឲ្យអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថនិងនីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដ៏ចម្បងសម្រាប់សម្រេចជំហានទី២ គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បន្តការតឹងតៀតចំណាយចរន្ត ដោយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ធ្វើវិចារណកម្មចំណាយ និងការធ្វើអាទិភាវូបនីយកម្មចំណាយ ជាពិសេស ត្រូវបន្តពង្រឹងការគោរពវិន័យដប់មួយយ៉ាងគឺការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ ត្រូវបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេស ដែលពុំសូវចាំបាច់ បន្ថយការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលមិនសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលមិនចាំបាច់។
- អនុវត្តឲ្យមានប្រសិទ្ធភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ ពិសេសគឺត្រូវជំរុញការអនុវត្តទស្សនាទានស្តីពីតម្លៃនៃលុយ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពចំណាយ។

- បន្តពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត និងមន្ត្រីជាប់កិច្ចសន្យា។

## III. សេចក្តីសន្និដ្ឋាន

១៤- ជារួម សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងល្អប្រសើរ ហើយកំពុងស្ថិតលើផ្លូវនៃកំណើនខ្ពស់ និងឈានទៅរកចីរភាព ទោះជាសេដ្ឋកិច្ចពិភពលោកមានដំណើរទៅមុខយឺតក៏ដោយ ជាពិសេសកម្ពុជាកំពុងតែស្ថិតក្នុងរបត់ផ្លាស់ប្តូរថ្មីមួយពីបរិមាណទៅគុណភាព ពោលគឺពីប្រទេសដែលមានចំណាត់ថ្នាក់ចំណូលទាបទៅរកប្រទេសមានចំណូលមធ្យមកម្រិតទាប ឬពីប្រទេសមានការអភិវឌ្ឍតិចតួចទៅកាន់ប្រទេសកំពុងអភិវឌ្ឍ នៅក្នុងរយៈពេលមធ្យមខាងមុខ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ គឺកំណើនសេដ្ឋកិច្ចត្រូវសម្រេចឲ្យបានប្រមាណ៧% និងអត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវរក្សាឲ្យស្ថិតក្នុងរង្វង់ដែលអាចគ្រប់គ្រងបានគឺក្នុងរង្វង់៣,៥%។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់សម្រេចឲ្យបាននូវអតិរេកចរន្តក្នុងរង្វង់៣%នៃផសស ក្នុងនោះ ឱនភាពថវិកាសរុបនឹងត្រូវកាត់បន្ថយមកនៅត្រឹម-៤,៨៩%នៃផសស ហើយនឹងត្រូវកាត់បន្ថយជាលំដាប់នៅក្នុងរយៈពេលមធ្យមខាងមុខឆ្ពោះទៅរកកម្រិតចីរភាពនៃថវិកាគឺក្នុងរង្វង់៣%នៃផសស ដូចមុនពេលមានវិបត្តិឆ្នាំ២០០៩។

១៥- ការកំណត់គោលដៅនៅក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោល-នយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ គឺជាកត្តាគន្លឹះក្នុងការធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងចីរភាព និងស្ថិរភាពនៃថវិកាដែលអាចឲ្យរាជរដ្ឋាភិបាលឈានទៅសម្រេចឲ្យបាននូវគោលដៅចម្បងរបស់ខ្លួនគឺ "ការធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេលវែង មានអត្រាខ្ពស់ប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ" និង "ការធានាសម្រេចឲ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឲ្យបានលើស១%ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ" និងឈានទៅសម្រេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជាទាំង៩។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគោលនយោបាយខាងលើ ក៏បានឆ្លុះបញ្ចាំងពីភាពចាំបាច់ក្នុងការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការកៀរគរចំណូលទាំងចំណូលសារពើពន្ធ ទាំងចំណូលមិនមែនសារពើពន្ធ និងការធ្វើវិចារណកម្មចំណាយឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន។

## IV. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១៦- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣-២០១៥របស់ខ្លួន និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៤-២០១៦

ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។ គំរូផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៤-២០១៦ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនេះរួមមាន៦ផ្នែកគឺ ៖

ផ្នែកទី១: សេចក្តីផ្តើម គឺជាការរៀបរាប់អំពីមុខងារ និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អំពីស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាក្នុងឆ្នាំកន្លងមក និងឆ្នាំកំពុងអនុវត្ត និងអំពីការចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដើម្បីសម្រេចបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ។

ផ្នែកទី២: គោលបំណងគោលនយោបាយ គឺជាគោលបំណងគោលនយោបាយរយៈពេលមធ្យម (ពី៣ទៅ៥ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង ស្ថាប័ន ហើយដែលត្រូវបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលជាយុទ្ធសាស្ត្រគោលនយោបាយដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។

ផ្នែកទី៣: កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព គឺជាកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២ ខាងលើ។ ការកំណត់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី៣.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

ផ្នែកទី៤: ការកំណត់សូចនាករ និងគោលដៅសូចនាករ គឺជាការកំណត់សូចនាករ និងគោលដៅសូចនាកររបស់គោលបំណងគោលនយោបាយ និងកម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ សម្រាប់តាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗដែលបានរៀបចំ ដើម្បីសម្រេចបាននូវគោលដៅនៃគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ដែលបានកំណត់។ សូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់ មកជាមួយសារាចរណែនាំនេះ។

ផ្នែកទី៥: ការកំណត់ធនធាន គឺជាការគ្រោងតម្រូវការចំណាយ និងចំណូលសម្រាប់រយៈពេល ៣ឆ្នាំ (២០១៤-២០១៦) ហើយការគ្រោងនេះគឺត្រូវគិតបញ្ចូលទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍។ ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ(២០១៤-២០១៦) ទៅតាមកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ដូចក្នុងតារាងទី៥.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។ ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ(២០១៤- ២០១៦) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឲ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និងចំណូលដែលបាន

មកពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួងស្ថាប័នដូចក្នុងតារាងទី៥.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។

ផ្នែកទី៦: សេចក្តីសន្និដ្ឋាន គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ និងការលើកទិសដៅ កម្មវិធីសកម្មភាព និងវិធានការ ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ ។

១៧- ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ និងឲ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឲ្យបានទាន់ពេលវេលាតាមកាលកំណត់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

# គំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់នឹងសារាចរ

# ផែនការយុទ្ធសាស្ត្រថវិកា
# សម្រាប់ឆ្នាំ២០១៤-២០១៦
# របស់ក្រសួង ស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត.........

## I. សេចក្តីផ្តើម

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយតាមវិស័យ ពិសេស **គោលនយោបាយរួមរបស់រាជរដ្ឋាភិបាល** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត........ មានគោលបំណងគោលនយោបាយដូចខាងក្រោម៖

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលនយោបាយណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ទី១:.................................. | | |
| ទី២:.................................. | | |

## III. កម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាព

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើអោយទទួលបានជោគជ័យក្រសួង ស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត....... បានរៀបចំកម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលមានដូចខាងក្រោម៖

## តារាង៣.១: កម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាព

គិតជាលានរៀល

| គោលបំណង គោលនយោបាយ | កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព | រយៈពេលអនុវត្ត | តម្រូវការឥណទានសរុប | ប៉ាន់ស្មានឥណទានបានអនុវត្តកន្លងមករហូតដល់ឆ្នាំ២០១៣ | តម្រូវការឥណទានបន្ត |
|---|---|---|---|---|---|
| គោលបំណងគ.ជទី១:.................... | ១.១:........................................................................................ | | | | |
| | ១.២:........................................................................................ | | | | |
| | ១.៣:........................................................................................ | | | | |
| | ១.៤:........................................................................................ | | | | |
| | ១.៥:........................................................................................ | | | | |
| គោលបំណងគ.បទី២:.................... | ២.១:........................................................................................ | | | | |
| | ២.២:........................................................................................ | | | | |
| | ២.៣:........................................................................................ | | | | |
| | ២.៤:........................................................................................ | | | | |
| | ២.៥:........................................................................................ | | | | |

## IV. ការកំណត់សូចនាករនិងគោលដៅសូចនាករ

ក្រសួង ស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត........បានកំណត់នូវសូចនាករនិងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធិផលនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនិងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោមៈ

**តារាង៤.១: ការកំណត់សូចនាករនិងគោលដៅសូចនាករ**

| គោលបំណងគោលនយោបាយនិងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព | ការកំណត់សូចនាករ | | ស្ថានភាពបច្ចុប្បន្នសូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | | | | គោលដៅសូចនាករលទ្ធផលចុងក្រោយ |
|---|---|---|---|---|---|---|---|---|---|
| | លទ្ធផលក្នុងឆ្នាំ | លទ្ធផលចុងក្រោយ | | ឆ្នាំ២០១៣ (ច្បាប់ហិ.) | ឆ្នាំ២០១៣ (សមិទ្ធផល) | ឆ្នាំ២០១៤ (គ្រោង) | ឆ្នាំ២០១៥ (គ្រោង) | ឆ្នាំ២០១៦ (គ្រោង) | |
| គោលបំណងគោលនយោបាយទី១:... ............................................ | | | | | | | | | |
| ១.១:.................................. | | | | | | | | | |
| ១.២:.................................. | | | | | | | | | |
| ....................................... | | | | | | | | | |
| គោលបំណងគោលនយោបាយទី២:... ............................................ | | | | | | | | | |
| ២.១:.................................. | | | | | | | | | |
| ២.២:.................................. | | | | | | | | | |
| ....................................... | | | | | | | | | |

# V. ការកំណត់ធនធាន

## ការកំណត់តម្រូវការចំណាយ

**តារាង៥.១: ការកំណត់តម្រូវការចំណាយ**

ឯកតាគិតជាលានរៀល

| គោលបំណងគោលនយោបាយ<br>កម្មវិធី/និងយុទ្ធសាស្ត្រអាទិភាព<br>ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុ<br>ឆ្នាំ២០១៣ | | | គ្រោងតម្រូវការឥណទានសម្រាប់<br>ឆ្នាំ២០១៤ | | | គ្រោងតម្រូវការឥណទានសម្រាប់<br>ឆ្នាំ២០១៥ | | | គ្រោងតម្រូវការឥណទានសម្រាប់<br>ឆ្នាំ២០១៦ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ |
| **សរុបរួម**<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>+គម្រោងវិនិយោគ<br>មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន<br>+ជំនួយបច្ចេកទេស<br>មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១. គោលបំណងគ.ប ទី១<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>+គម្រោងវិនិយោគ<br>មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន<br>+ជំនួយបច្ចេកទេស | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាពទី ១<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>+គម្រោងវិនិយោគ<br>មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន<br>+ជំនួយបច្ចេកទេស<br>មានហិរញ្ញប្បទាន<br>មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.២: កម្មវិធី-យុទ្ធសាស្ត្រអាទិភាពទី ២<br>.............................................<br>............................................. | | | | | | | | | | | | |

កំណត់សម្គាល់:

+ គម្រោងមានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងដំណើរការនិងគម្រោងដែលបានចុះកិច្ចសន្យារួច

+ គម្រោងមិនទាន់មានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងចរចារនិងគម្រោងកំពុងស្វែងរកហិរញ្ញប្បទាន

## ការគ្រោងចំណូល

ដើម្បីរួមចំណែកដល់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលធនធានដើម្បីសំរេចឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ក្រសួងស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត......... បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម៖

ក.....................................................

ខ.....................................................

តាមរយៈយុទ្ធសាស្ត្រនេះ ក្រសួង ស្ថាប័ន/មន្ទីរជំនាញរាជធានី ខេត្ត.............. បានគ្រោងចំណូលដូចខាងក្រោម៖

**តារាង៥.២៖ ការគ្រោងចំណូល**

ឯកតាគិតជាលានរៀល

| ប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ | | គ្រោងឆ្នាំ២០១៤ | | គ្រោងឆ្នាំ២០១៥ | | គ្រោងឆ្នាំ២០១៦ | |
|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ |
| សរុបរួម | | | | | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>-ចំណូលសារពើពន្ធ<br>-ចំណូលមិនមែនសារពើពន្ធ<br>-ចំណូលមូលធនក្នុងស្រុក(កម្ចីបន្ត) | | | | | | | | |
| ២. ចំណូលពីការអនុវត្តកម្មវិធី/គម្រោង<br>- គម្រោងវិនិយោគ(មានហិរញ្ញប្បទាន)<br>+គម្រោង/កម្មវិធី...........................<br>+គម្រោង/កម្មវិធី...........................<br>- ជំនួយបច្ចេកទេស(មានហិរញ្ញប្បទាន)<br>+គម្រោង/កម្មវិធី...........................<br>+គម្រោង/កម្មវិធី........................... | | | | | | | | |

## VI. សេចក្តីសន្និដ្ឋាន

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

រាជធានីភ្នំពេញ, ថ្ងៃទី............ខែ................ឆ្នាំ...................

**រដ្ឋមន្ត្រី**